**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្តាល

លេខ: ០៥៤/១៥ សស.គគ

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម

ភ្នំពេញ,ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ ២០១៥

# សេចក្តីសម្រេច
# ស្តីពីតួនាទី ភារកិច្ច និងអង្គការចាត់តាំង
# នៃគណៈឃោសនាអប់រំ គណៈកម្មាធិការកណ្តាល

*******

**យោង** ៖ - សេចក្តីសម្រេចរបស់គណៈកម្មាធិការមជ្ឈិម លេខ ០២ សកសរចមឈ. ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ១៩៧៩

- សេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍មជ្ឈិមបក្សលេខ ៨៦ សរមឈ. ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ១៩៨០ អំពី ភារកិច្ច និងអង្គការចាត់តាំងនៃគណៈឃោសនាអប់រំមជ្ឈិម
- សេចក្តីសម្រេចរបស់គណៈលេខាមជ្ឈិមបក្ស លេខ ១៨៣ សរមឈ. ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៨៥ អំពី តួនាទី ភារកិច្ច និងអង្គការចាត់តាំងនៃគណៈឃោសនាអប់រំមជ្ឈិម
- សេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល លេខ ៥០១ សស.គក ចុះថ្ងៃទី ៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩២ ស្តីពីការកែសម្រួលក្របខណ្ឌដោយឡែករបស់ស្ថាប័នគណបក្ស និងអង្គការសង្គមនៅថ្នាក់កណ្តាល ខេត្ត ក្រុង ស្រុក ខណ្ឌ ទីរួមខេត្ត
- សេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល លេខ ២០៣០ សស.គក ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០០ ស្តីពីតួនាទី ភារកិច្ច អង្គការចាត់តាំង និងរបៀបរបបធ្វើការរបស់គណៈឃោសនាអប់រំគណៈកម្មាធិការកណ្តាល
- សំណូមពរនៃភារកិច្ចនយោបាយរបស់គណបក្សក្នុងដំណាក់កាលបច្ចុប្បន្ន
- ស្មារតីនៃអង្គប្រជុំគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល នាថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៥ ។

## គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលសម្រេច :

**ប្រការ ១** : គណៈឃោសនាអប់រំគណៈកម្មាធិការកណ្តាលមានតួនាទីជាស្ថាប័នជំនួយការរបស់គណៈកម្មាធិការកណ្តាល អំពីការងារសតិអារម្មណ៍ ជួយគណៈកម្មាធិការកណ្តាលដើម្បីដឹកនាំ និងពិនិត្យមើលការអនុវត្តការងារឃោសនា និងអប់រំនយោបាយ សតិអារម្មណ៍របស់គណបក្សនៅគ្រប់ថ្នាក់ គ្រប់ផ្នែក ជំរុញលើកទឹកចិត្តដល់ការអនុវត្តកម្មវិធីនយោបាយ គោលការណ៍

គោលនយោបាយ សេចក្តីសម្រេចនានារបស់គណបក្ស និងរួមចំណែកក្នុងការកសាងគណបក្ស កសាងបណ្តាអង្គការចាត់តាំង និងធនធានមនុស្សរបស់គណបក្ស ។

**គណៈឃោសនាអប់រំគណៈកម្មាធិការកណ្តាល មានភារកិច្ច ដូចខាងក្រោម ៖**

**ក**- ផ្អែកលើសេចក្តីសម្រេចទាំងឡាយរបស់គណបក្ស ធ្វើការស្រាវជ្រាវសភាពការណ៍សតិអារម្មណ៍ទាំងក្នុងគណបក្ស ទាំងក្នុងមហាជន ហើយធ្វើសំណើជូនគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលនូវគោលការណ៍ ខ្លឹមសារ និងផែនការឃោសនាអប់រំក្នុងគណបក្ស ក្នុងមហាជន អំពីកម្មវិធីនយោបាយ គោលការណ៍ គោលនយោបាយ និងសេចក្តីសម្រេចនានារបស់គណបក្ស ព្រមទាំងបច្ចុប្បន្នភាពនៃសភាពការណ៍ក្នុងប្រទេស និងក្រៅប្រទេស ដើម្បីជានាការអនុវត្តរាល់ភារកិច្ចនយោបាយរបស់គណបក្សឲ្យបានល្អ ។

**ខ**- តាមដាន ស្វែងយល់ វិភាគសកម្មភាព និងឧបាយកលរបស់ពួកអមិត្ត និងបណ្តាមជ្ឈដ្ឋានអគតិលើវិស័យសតិអារម្មណ៍ ហើយលើកសំណើជូនគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលអំពីគោលការណ៍ ទិសដៅ ខ្លឹមសារ និងផែនការតស៊ូក្នុងសមរភូមិសតិអារម្មណ៍ឲ្យបានសមស្របទាន់ពេលវេលា ។

**គ**- ដាស់តឿន ក្រើនរំឭក ពិនិត្យមើលការអនុវត្តភារកិច្ចឃោសនា អប់រំនយោបាយ សតិអារម្មណ៍របស់គណបក្សបណ្តាថ្នាក់ បណ្តាផ្នែក ដើម្បីដឹកនាំ ពង្រឹង និងកែលម្អឲ្យទាន់ពេលវេលា ។

**ឃ**-ស្រាវជ្រាវ រៀបចំផែនការ កម្មវិធី ខ្លឹមសារអប់រំនយោបាយ ស្នើជូនគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ដើម្បីចាត់តាំងវគ្គសិក្សាអប់រំបណ្តុះបណ្តាល បំពាក់បំប៉នជូរមន្ត្រីរបស់គណបក្សនៅគ្រប់ថ្នាក់ គ្រប់ផ្នែក សំដៅពង្រឹង លើកកម្ពស់គុណធម៌ និងសមត្ថភាពធ្វើការរបស់មន្ត្រីគណបក្ស ។ ចាត់តាំងការបណ្តុះបណ្តាលបំប៉នជំនាញដល់មន្ត្រីនៃគណៈឃោសនាអប់រំរាជធានី ខេត្ត ក្រសួង ស្ថាប័ន និងមន្ត្រីនៃគណៈឃោសនាអប់រំក្រុង ស្រុក ខណ្ឌ ។

**ង**- សហការពង្រឹងប្រព័ន្ធឃោសនា និងផ្សព្វផ្សាយ ដើម្បីជំរុញការអនុវត្តគោលការណ៍ខ្លឹមសារ ផែនការឃោសនា អប់រំនយោបាយ សតិអារម្មណ៍ក្នុងគណបក្ស និងក្នុងមហាជន ព្រមទាំងពង្រឹង ពង្រីកប្រៀបរបស់គណបក្សក្នុងវិស័យព័ត៌មាន និងសាធារណមតិ ។

**ប្រការ ២** : រចនាសម្ព័ន្ធអង្គការចាត់តាំងនៃគណៈឃោសនាអប់រំគណៈកម្មាធិការកណ្តាល រួមមាន ៖

**ក**- គណៈឃោសនាអប់រំគណៈកម្មាធិការកណ្តាល មានប្រធាន១រូប និងមានអនុប្រធានមួយចំនួន ។

- ប្រធានដឹកនាំរួមលើរាល់ការងាររបស់គណៈឃោសនាអប់រំ ។
- អនុប្រធាន មានភារកិច្ចជួយប្រធានទទួលបន្ទុកការងារមួយចំនួនដែលប្រធានប្រគល់ឲ្យ និងជំនួសប្រធាននៅពេលប្រធានអវត្តមាន តាមការប្រគល់ភារកិច្ចរបស់ប្រធាន ។

**ខ**- គណៈឃោសនាអប់រំគណៈកម្មាធិការកណ្តាល មានមន្ទីរ និង ៤ នាយកដ្ឋានចំណុះ គឺ ៖

១. មន្ទីរ ៖

+ មន្ទីរមានភារកិច្ច ៖

- ធ្វើការងាររដ្ឋបាល

- ការងាររបៀប និងពិធីការ

- ការងារបូកសរុប

- ការងារភស្តុភារ គណនេយ្យ ហិរញ្ញកិច្ច

- ការងារបុគ្គលិក

- ការងារគ្រប់គ្រងថែរក្សាឯកសារ ។

+ មន្ទីរមានប្រធាន ១រូប និងអនុប្រធានមួយចំនួន ហើយមានការិយាល័យចំណុះ ចំនួន ៣ គឺ ៖

- ការិយាល័យរដ្ឋបាល គ្រប់គ្រង

- ការិយាល័យសរុប

- ការិយាល័យតម្កល់ឯកសារ ។

**២.នាយកដ្ឋានឃោសនា ៖**

+ នាយកដ្ឋានឃោសនាមានភារកិច្ច ៖

- ស្រាវជ្រាវ វិភាគ លើកទិសដៅ ផែនការ ខ្លឹមសារសម្រាប់ឃោសនាដល់សមាជិកគណបក្ស មហាជន និងមជ្ឈដ្ឋាននានាឲ្យយល់ច្បាស់អំពីគោលការណ៍ គោលនយោបាយ សេចក្តីសម្រេច និងសកម្មភាពនានារបស់គណបក្ស ។

- ស្រាវជ្រាវ ស្វែងយល់សកម្មភាពរបស់ពួកអមិត្ត និងមជ្ឈដ្ឋានអគតិនានាដែលមានគោលដៅប្រឆាំងគណបក្សខាងនយោបាយ សតិអារម្មណ៍ ហើយរៀបចំចងក្រងឯកសារបកស្រាយបំភ្លឺមហាជន និងវាយបកលើមជ្ឈដ្ឋានទាំងនោះឲ្យបានទាន់ពេលវេលា ។

- រៀបចំការផ្សព្វផ្សាយឯកសារនានារបស់គណបក្ស។

- បំពាក់បំប៉នបាឋកថា និងឃោសកិសម្រាប់ការឃោសនា និងផ្សព្វផ្សាយគោលការណ៍ គោលនយោបាយ និងសកម្មភាពរបស់គណបក្ស ។

- តាមដានជំរុញការងារឃោសនារបស់គណបក្សនៅគ្រប់ថ្នាក់ ពង្រឹងចរិតមហាជន ចរិតវាយសម្រុក និងចរិតជាប់មិនដាច់នៃការងារឃោសនា ។

- ធ្វើទំនាក់ទំនងជាមួយគណៈឃោសនាអប់រំរាជធានី ខេត្ត និងក្រសួង ស្ថាប័ន ដើម្បីក្តាប់សភាពការណ៍ទូទៅ និងជំរុញអនុវត្តការងារឃោសនា។

- តាមដានការផ្សាយនៃបណ្តាញគេហទំព័រសង្គម ។

+ នាយកដ្ឋានឃោសនាមានប្រធាន ១រូប និងអនុប្រធានមួយចំនួន ហើយមានការិយាល័យចំណុះ ចំនួន ៣ គឺ ៖

- ការិយាល័យរៀបចំឯកសារ និងផ្សព្វផ្សាយ
- ការិយាល័យទំនាក់ទំនងរាជធានី ខេត្ត និងក្រសួង ស្ថាប័ន
- ការិយាល័យគេហទំព័រសង្គម ។

**៣. នាយកដ្ឋានព័ត៌មាន ៖**

+ នាយកដ្ឋានព័ត៌មាន មានភារកិច្ច ៖
- ប្រមូល និងវិភាគព័ត៌មានជាតិ និងអន្តរជាតិ ដែលទាក់ទងនឹងវិស័យផ្សេងៗ ដើម្បីបម្រើឲ្យការឃោសនា អប់រំនយោបាយ សតិអារម្មណ៍។
- ធ្វើទំនាក់ទំនងជាមួយបណ្ដាញព័ត៌មាន ដើម្បីជំរុញការឃោសនា និងផ្សព្វផ្សាយអំពីសភាពការណ៍ គោលនយោបាយ សកម្មភាពរបស់គណបក្ស។
- តាមដានការផ្សាយនៃបណ្ដាញព័ត៌មាន រួមទាំងបណ្ដាញព័ត៌មានសង្គម ដើម្បីធ្វើការសម្របសម្រួលលើការងារព័ត៌មាន ។
- សហការជាមួយបណ្ដាអង្គភាពព័ត៌មាន ដើម្បីធ្វើការឆ្លើយតបឲ្យទាន់ពេលចំពោះព័ត៌មានអវិជ្ជមាន ពីសំណាក់មជ្ឈដ្ឋានអគតិ ឬពីប្រភពផ្សេងៗទៀត ។

+ នាយកដ្ឋានព័ត៌មានមានប្រធាន ១រូប និងអនុប្រធានមួយចំនួន ហើយមានការិយាល័យចំណុះ ចំនួន ២ គឺ ៖
- ការិយាល័យព័ត៌មានជាតិ
- ការិយាល័យព័ត៌មានអន្តរជាតិ ។

**៤. នាយកដ្ឋានទស្សនាវដ្ដីប្រជាជន ៖**

+ នាយកដ្ឋានទស្សនាវដ្ដីប្រជាជនមានភារកិច្ច ៖
- ស្រាវជ្រាវ រៀបចំខ្លឹមសារអត្ថបទដែលទាក់ទងបណ្ដាវិស័យសម្រាប់ការចេញផ្សាយទស្សនាវដ្ដីជារៀងរាល់ខែ បម្រើឲ្យការឃោសនា អប់រំនយោបាយ សតិអារម្មណ៍ ។
- ស្រាវជ្រាវ រៀបចំព្រឹត្តិប័ត្រព័ត៌មាន តាមការចាំបាច់ ។
- គ្រប់គ្រងការបោះពុម្ព និងចែកផ្សាយទស្សនាវដ្ដីឲ្យបានដល់គោលដៅ ។
- ដំណើរការគេហទំព័រទស្សនាវដ្ដីប្រជាជន ។

+ នាយកដ្ឋានទស្សនាវដ្ដីប្រជាជន មានប្រធាន ១រូប និងអនុប្រធានមួយចំនួន ហើយមានការិយាល័យចំណុះចំនួន ៣ គឺ ៖
- ការិយាល័យនិពន្ធ
- ការិយាល័យលេខានិពន្ធ បោះពុម្ព និងចែកផ្សាយ
- ការិយាល័យគេហទំព័រ ។

**៥. នាយកដ្ឋានអប់រំនយោបាយ ៖**

+ នាយកដ្ឋានអប់រំនយោបាយមានភារកិច្ច ៖

- រៀបចំផែនការបណ្តុះបណ្តាល បំពាក់បំប៉នមន្ត្រី និងសកម្មជនរបស់គណបក្សគ្រប់ថ្នាក់គ្រប់ផ្នែក តាមដំណាក់កាលនីមួយៗ និងតាមពេលវេលានីមួយៗតាមការចាំបាច់។
- ស្រាវជ្រាវ រៀបចំកម្មវិធី ខ្លឹមសារបណ្តុះបណ្តាល បំពាក់បំប៉នមន្ត្រីគណបក្ស អំពីនយោបាយ ការងារកសាងគណបក្ស និងមុខជំនាញឃោសនាអប់រំ ។
- ចាត់តាំងវគ្គសិក្សាតាមផែនការដែលបានកំណត់ ។
- បណ្តុះបណ្តាលគ្រូឧទ្ទេសនាមរបស់គណបក្សរាជធានី ខេត្ត សម្រាប់ការអប់រំបន្ត ។
- តាមដាន វាយតម្លៃលទ្ធផលនៃវគ្គសិក្សានីមួយៗ ។
- ទំនាក់ទំនង និងកសាងគ្រូឧទ្ទេសនាម សម្រាប់វគ្គសិក្សានីមួយៗ។
- ទំនាក់ទំនង និងសហការជាមួយអង្គការមហាជន និងអង្គការសង្គមផ្សេងៗលើការងារអប់រំបណ្តុះបណ្តាលមន្ត្រីគណបក្ស ។
- លើកគម្រោងចំណាយ សម្រាប់វគ្គសិក្សានីមួយៗ ។

\+ នាយកដ្ឋានអប់រំនយោបាយ មានប្រធាន ១រូប និងអនុប្រធានមួយចំនួន ហើយមានការិយាល័យចំណុះចំនួន ៤ គឺ ៖

- ការិយាល័យផែនការ
- ការិយាល័យខ្លឹមសារ
- ការិយាល័យអប់រំសិក្សា
- ការិយាល័យសរុប ។

**ប្រការ ៣** : គណៈឃោសនាអប់រំគណៈកម្មាធិការកណ្តាលត្រូវបន្តស្រាវជ្រាវ ពិនិត្យលើភារកិច្ចដែលត្រូវអនុវត្តស្របតាមសំណូមពរការងារជាក់ស្តែង និងបែងចែកប្រគល់ភារកិច្ចច្បាស់លាស់ដល់មន្ត្រីក្រោមឱវាទឲ្យអនុវត្តបានល្អ ។

**ប្រការ ៤** : សេចក្តីសម្រេចនេះជំនួសឲ្យសេចក្តីសម្រេចមុនៗ អំពី តួនាទី ភារកិច្ច និងអង្គការចាត់តាំងនៃគណៈឃោសនាអប់រំគណៈកម្មាធិការកណ្តាល ។

**ប្រការ ៥** : ខុទ្ទកាល័យគណៈកម្មាធិការកណ្តាល គណៈចាត់តាំងគណៈកម្មាធិការកណ្តាល គណៈ-ឃោសនាអប់រំគណៈកម្មាធិការកណ្តាល និងបណ្តាស្ថាប័នគណបក្សដែលពាក់ព័ន្ធមានភារៈអនុវត្តសេចក្តីសម្រេចនេះ ។

**ជ.គណៈអចិន្ត្រៃយ៍**

**ប្រធានស្តីទី**

**ហ៊ុន សែន**